ប្រការ ៨ : សេចក្តីសំរេចនេះចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

រាជធានីភ្នំពេញ,ថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩៩

## សេចក្តីសំរេចលេខ ៦៩ សសរ

## ស្តីពីការបង្កើតគណៈកម្មការដោះស្រាយបាតុភាពនៅក្នុងតំបន់ ឧទ្យានជាតិព្រះមុនីវង្ស " បូកគោ " និងឧទ្យានជាតិកែប

***

### រាជរដ្ឋាភិបាល

- **បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា**
- **បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា**
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការបង្កើត និងកំណត់តំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញសេចក្តីជូនដំណឹងលេខ ១០៧៣ សជណ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញភាពចាំបាច់នៃការគ្រប់គ្រងតំបន់ឧទ្យានជាតិព្រះមុនីវង្ស " បូកគោ " និងកែប

### សំរេច

ប្រការ ១ : តែងតាំងគណៈកម្មការដោះស្រាយបាតុភាពនៅក្នុងតំបន់ឧទ្យានជាតិព្រះមុនីវង្ស " បូកគោ " និងក្រុងកែប ដែលមានសមាសភាពដូចខាងក្រោម ៖

១-ឯកឧត្តម ឆាន់ សាផាន រដ្ឋលេខាធិការក្រសួងបរិស្ថាន ជាប្រធាន

| | |
|---|---|
| ២-លោកឧត្តម ឌិត ត្រឿនទុន្ធា អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន | ជាអនុប្រធានប្រចាំការ |
| ៣-លោកឧត្តម ម៉ុល សឹម អគ្គាធិការរងនៃអគ្គាធិការដ្ឋាន ក្រសួងមហាផ្ទៃ | ជាអនុប្រធាន |
| ៤-លោកឧត្តម ឌី ស៊ី អភិបាល ខេត្តកំពត | ជាអនុប្រធាន |
| ៥-លោកឧត្តម នាន ឈៀ អភិបាលរងទី១ ក្រុងកែប | ជាអនុប្រធាន |
| ៦-លោកឧត្តម ឈឹម ជួន អភិបាលរងទី១ ខេត្តកំពត | សមាជិក |
| ៧-លោកឧត្តម ខៀវ មុត អគ្គនាយក ក្រសួងបរិស្ថាន | សមាជិក |
| ៨-លោកឧត្តម យ៉ារ ឡេងហាត់ ជំនួយការអមទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៩-លោកស្រី ចាយ សារិទ្ធ ប្រធាននាយកដ្ឋានការពារអភិរក្សធម្មជាតិ | សមាជិក |
| ១០-លោក ឈឹម ហោ ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ | សមាជិក |
| ១១-តំណាង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១២-តំណាង អគ្គនាយកដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ | សមាជិក |
| ១៣-ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្មនិងសំណង់ខេត្តកំពត | សមាជិក |
| ១៤-ប្រធានមន្ទីរកសិកម្ម ក្រុងកែប | សមាជិក |
| ១៥-ប្រធានមន្ទីរបរិស្ថានខេត្តកំពត | សមាជិក |
| ១៦-ប្រធានមន្ទីរបរិស្ថាន ក្រុងកែប | សមាជិក |
| ១៧-អភិបាលស្រុកកំពត | សមាជិក |
| ១៨-អភិបាលសង្កាត់កែប | សមាជិក |
| ១៩-នាយកឧទ្យានជាតិព្រះមុនីវង្ស " បូកគោ " | សមាជិក |

ប្រការ ២ : ភារកិច្ចរបស់គណៈកម្មការ មាន :

- ចុះពិនិត្យដោះស្រាយបញ្ហាកាន់កាប់ដីធ្លីនៅក្នុងតំបន់ឧទ្យានជាតិព្រះមុនីវង្ស " បូកគោ " និង ឧទ្យានជាតិកែប តាមស្មារតីនៃសេចក្តីជូនដំណឹងលេខ : ១០៣៧ សជណ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៩៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ។
- ធ្វើសេចក្តីរាយការណ៍ និងលើកយោបល់ស្នើសុំចំពោះវិធានការជាក់ស្តែងជូនសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល ។

ប្រការ ៣ : លេខាធិការដ្ឋានគណៈកម្មការ ដែលតំណាងឲ្យក្រសួង ស្ថាប័ន ខេត្តក្រុងពាក់ព័ន្ធ ត្រូវទទួលខុសត្រូវក្នុងក្របខ័ណ្ឌសមត្ថកិច្ច ភារកិច្ចដែលបានចែងក្នុងប្រការ ២ ខាងលើ និងត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការ និងមានសិទ្ធិបង្គាប់ការលើមន្ត្រីជំនាញផ្ទាល់ស្ថិតនៅក្រោមឱវាទរបស់ខ្លួន ។

ប្រការ ៤ : រាល់ការចំណាយ និងសម្ភារៈបរិក្ខារសំរាប់បំពេញការងារ ត្រូវលើកជាគោលការណ៍ថវិការដ្ឋ ។

ប្រការ ៥ : គណៈកម្មការមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងបរិស្ថាន ។

ប្រការ ៦ : ទេសរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ទេសរដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួងពាក់ព័ន្ធ អភិបាលខេត្តក្រុងប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអភិបាលក្រុងកែប ត្រូវអនុវត្តសេចក្តីសំរេចនេះឲ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ជ.នាយករដ្ឋមន្ត្រី
ឧបនាយករដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
ស ខេង

***

# III- ការងារបណ្តាក្រសួង

## ១-ទីស្តីការរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

### ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី១២ ខែតុលា ឆ្នាំ១៩៩៩

### ប្រកាសលេខ ២១២ មខ.ប្រក

### ស្តីពីការបង្កើតក្រុមការងារអន្តរក្រសួង

***

### រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ/បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍